ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ២៥៣

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

**សាលក្រមរដ្ឋប្បវេណីលេខ**

**២៥ (ជ)**

ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤

# ក្នុងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយមានសមាសភាព

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៣ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមាន៖

ដើមចោទឈ្មោះ [redacted] ដារ៉ា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្ននៅ [redacted]

ដោយមានលោក [redacted] ជាអ្នកតំណាងដោយអាណត្តិ មានអត្តលេខ ២៦២២T មាន [redacted]

ចុងចម្លើយឈ្មោះ [redacted] សុខគីម ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្ននៅ [redacted]

## អង្គហេតុ និងចំណុចវិវាទ

**១./ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១.១./ សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុខគីម។

១.២./ សុំសិទ្ធិអំណាចមេបាគ្រប់គ្រងកូនចំនួន ០៣នាក់

ក. ឈ្មោះ [redacted] ហេងលីគ័ង្គ ភេទប្រុស កើតថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧

ខ. ឈ្មោះ [redacted] ហេងម៉ីជីង ភេទស្រី កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨



Scanned with CamScanner

គ.[redacted] ហេងម៉េងហុង ភេទប្រុស ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

១.៣./ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## ២./ អង្គហេតុនៃការទាមទារ

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ២០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ក្រោយពេលរៀបការរួចហើយពួកខ្លួនមានកូនចំនួន ០៣ នាក់ ១.ឈ្មោះ [redacted] ហេងលីគ័ង្គ ភេទប្រុស កើតថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧, ២.ឈ្មោះ [redacted] ហេងម៉ីជីង ភេទស្រី កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ និង៣.ឈ្មោះ [redacted] ហេងម៉េងហុង ភេទប្រុស កើតថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ចំពោះទ្រព្យសម្បត្តិរួមមាន បំណុលរួមក៏មានដែរ។ ដោយសារតែចុងចម្លើយឈ្មោះ **សៀ សុខគីម** បានចុះចោលរូបខ្ញុំបាទ និងកូននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ដោយគ្មានការជូនដំណឹងមកខ្ញុំបាទ ជាហេតុឱ្យខ្ញុំអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ទើបខ្ញុំបាទសម្រេចចិត្តដាក់ពាក្យបណ្តឹងមកឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីជួយចេញសាលក្រមតាមស្នើសុំដោយក្តីអនុគ្រោះ។

## ៣./ ការសាកល្បងផ្សះផ្សា

តុលាការបានធ្វើការសាកល្បងផ្សះផ្សាភាគីដើមចោទ និងភាគីចុងចម្លើយ គ្រប់ពេលដែលភាគីទាំងពីរបានចូលរួមក្នុងនីតិវិធីរបស់តុលាការ ប៉ុន្តែភាគីទាំងសងខាងមិនមានឆន្ទៈក្នុងការរួមរស់នៅជាមួយគ្នាវិញនោះទេ។

## ៤./ ការអះអាងរបស់គូភាគី

ដើមចោទឈ្មោះ **មៀង ដារ៉ា** បានធ្វើការអះអាងថា៖

នៅពេលនេះខ្លួនសូមរក្សាខ្លឹមសារនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ទុកជាបានការដដែលដោយមិនមានអ្វីផ្លាស់ប្តូរនោះទេ។

ចុងចម្លើយឈ្មោះ [redacted] **សុខគីម** បានធ្វើការអះអាងថា៖

នៅក្នុងពេលនេះខ្លួនបានដឹងពីការទាមទាររបស់ភាគីដើមចោទរួចហើយ ខ្លួនសូមឯកភាពចំពោះការទាមទាររបស់ភាគីដើមចោទត្រង់ចំណុចទី១ គឺខ្លួនយល់ព្រមលែងលះពីភាគីដើមចោទ។ ចំពោះការទាមទារត្រង់ចំណុចទី២ ដែលដើមចោទទាមទារកូនទាំងអស់ ត្រង់ចំណុចនេះខ្លួនមិនយល់ព្រមនោះទេ ដោយខ្លួនសុំទាមទារកូនចំនួន ០២នាក់ ដោយហេតុថា កូនទាំងពីរនាក់ដែលខ្លួនទាមទារ គឺកំពុងរស់នៅ និងមើលថែរក្សាជាមួយខ្លួនស្រាប់។ កូនទាំងពីរនាក់ដែលកំពុងតែរស់នៅជាមួយខ្លួនមានឈ្មោះ [redacted] ហេងលីគ័ង្គ ភេទប្រុស និងឈ្មោះ [redacted] ហេងម៉េងហុង ភេទប្រុស ចំពោះកូនទី២ ឈ្មោះ [redacted] ហេងម៉ីជីង ភេទស្រី សព្វថ្ងៃកំពុងរស់នៅជាមួយប្តីរបស់ខ្លួនស្រាប់។

ដូច្នេះ នៅពេលនេះ ខ្លួនសូមធ្វើការទាមទារកូនទាំងពីរនាក់ដែលកំពុងតែរស់នៅជាមួយខ្លួនមានឈ្មោះ [redacted] ហេងលីគ័ង្គ ភេទប្រុស និងឈ្មោះ[redacted] ហេងម៉េងហុង ភេទប្រុស មកខ្លួនជាអ្នកមានសិទ្ធិអំណាច



Scanned with CamScanner

មេបា ចំពោះកូនទីពីរឈ្មោះ [redacted] ហៅងម៉ីជឹង គឺ ប្រគល់ឱ្យដើមចោទ ជាអ្នកមានសិទ្ធិអំណាចមេបា។

ចំពោះប្រាក់ប្រដាប់ក្តីខ្លួនយល់ព្រមឱ្យភាគីដើមចោទជាអ្នករ៉ាប់រង។

ដើមចោទឈ្មោះ [redacted] ដារ៉ា បានធ្វើការអះអាងតបថា៖

នៅពេលនេះខ្លួនសូមឯកភាពចំពោះការទាមទារកូនចំនួនពីរនាក់មានឈ្មោះ [redacted] ហៅងលីគ័ង្គ ភេទប្រុស និងឈ្មោះ [redacted] ហៅងម៉េងហុង ភេទប្រុស របស់ភាគីចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបា និងប្រគល់សិទ្ធិអំណាចមេបាឱ្យមកខ្លួនជាអ្នកគ្រប់គ្រងកូនស្រីឈ្មោះ [redacted] ហៅងម៉ីជឹង។

**៥./ ចំណុចវិវាទ**

១./តើការទាមទារលែងលះរបស់ដើមចោទធ្វើឡើងមានមូលហេតុត្រឹមត្រូវតាមផ្លូវច្បាប់ដែរ ឬទេ?

២./តើដើមចោទមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់សម្រាប់គ្រប់គ្រងកូនឈ្មោះ [redacted] ហៅងម៉ីជឹង ភេទស្រី ដែរឬទេ?

៣./តើចុងចម្លើយមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់សម្រាប់គ្រប់គ្រងកូនឈ្មោះ [redacted] ហៅងលីគ័ង្គ ភេទប្រុស និងឈ្មោះ [redacted] ហៅងម៉េងហុង ភេទប្រុស ដែរឬទេ?

**៦./ ភស្តុតាងដែលដាក់ដោយភាគីដើមចោទ**

-សំបុត្រអាពាហ៍ពិពាហ៍លេខ ២០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ចេញដោយមន្រ្តីអត្រានុកូលដ្ឋានឃុំស្តុក។

-សំបុត្រកំណើតលេខ ៥៩ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ចេញដោយមន្រ្តីអត្រានុកូលដ្ឋានឃុំស្តុក។

-សំបុត្របញ្ជាក់កំណើតលេខ ៨៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ចេញដោយមន្រ្តីអត្រានុកូលដ្ឋានឃុំស្តុក។

-សំបុត្រកំណើតលេខ ៧៨ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ចេញដោយមន្រ្តីអត្រានុកូលដ្ឋានឃុំស្តុក។

## សំអាងហេតុ

**១.ការវិនិច្ឆ័យអំពីការលែងលះ**

-តាមការអះអាងរបស់ភាគីដើមចោទ និងភាគីចុងចម្លើយ ក្នុងការទាញហេតុផលដោយផ្ទាល់មាត់បានលើកឡើងថា ភាគីទាំងពីរបានយល់ព្រមលែងលះពីគ្នា ហើយមិនមានឆន្ទៈក្នុងការបន្តចំណងអាពាហ៍ពិពាហ៍នឹងគ្នាតទៅទៀតបាន ដែលទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានិងអាចបង្កើតទៅរកភាពដើមវិញនោះទេ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**២.ការវិនិច្ឆ័យអំពីអំណាចមេបា**

-តាមអះអាងរបស់ដើមចោទ និងចុងចម្លើយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ភាគីទាំងសងខាងបានពិភាក្សា និងបង្ហាញឆន្ទៈក្នុងការកំណត់យកដើមចោទឈ្មោះ [redacted] ដារ៉ា ជាអ្នកមានសិទ្ធិ



Scanned with CamScanner

អំណាចមេបាលើកូនស្រីឈ្មោះ [redacted] ហេងម៉ីជឹង កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ និងចុងចម្លើយឈ្មោះ [redacted] សុខគីម ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនចំនួនពីរនាក់ មាន១.ឈ្មោះ [redacted] ហេងលីគ័ង្គ ភេទប្រុស កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ និងទី២.ឈ្មោះ [redacted] ហេងម៉េងហុង ភេទប្រុស កើតថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៣.បន្ទុកនៃប្រាក់ប្រដាប់ក្តី**

តាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ ។

**ហេតុដូច្នេះ សម្រេច**

១./ ឱ្យដើមចោទឈ្មោះ [redacted] ដារ៉ា លែងលះពីចុងចម្លើយឈ្មោះ [redacted] សុខគីម ។

២./ កំណត់យកដើមចោទឈ្មោះ [redacted] ដារ៉ា ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ហេងម៉ីជឹង ភេទស្រី កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩។

៣./ កំណត់យកចុងចម្លើយឈ្មោះ [redacted] សុខគីម ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនពីរនាក់៖

៣.១.ឈ្មោះ [redacted] ហេងលីគ័ង្គ ភេទប្រុស កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧

៣.២.ឈ្មោះ [redacted] ហេងម៉េងហុង ភេទប្រុស កើតថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

៤./ ប្រាក់ប្រដាប់ក្តីជាបន្ទុក របស់ដើមចោទ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខដើមចោទ និងចុងចម្លើយ។ ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

| **ក្រឡាបញ្ជី** | **ចៅក្រម** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានឃើញ

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កំពង់ស្ពឺ, ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner